ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកណ្ដាល**

គណៈកម្មាធិការលទ្ធកម្ម

លេខ ៖ ............សជណ.អល.កណ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្ដីជូនដំណឹង

## ស្ដីពីការងារដាក់បង្គោលភ្លើងបំភ្លឺសាធារណៈចំនួន០៥គម្រោង ជូនសាលាខេត្ត

ខេត្តកណ្ដាល សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុនសំណង់ (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាខេត្តកណ្ដាលនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារដាក់បង្គោលភ្លើងបំភ្លឺសាធារណៈចំនួន០៥គម្រោង ជូនសាលាខេត្ត៖

- ការងារដាក់បង្គោលដងគោមអគ្គីសនីដៃមួយ កម្ពស់ 8m ប្រវែង 1,950m ចំនួន 68បង្គោល នៅសង្ខាងផ្លូវជើងភ្នំព្រះរាជទ្រព្យ ពីចំណុចច្រមុះជ្រូកទៅដល់វត្តអរិយក្សេប ស្ថិតក្នុងឃុំផ្សារដែក ស្រុកពញាឮ
- ការងារជួសជុលដាក់បង្គោលភ្លើងចំនួន 4គម្រោង ស្ថិតក្នុងក្រុងតាខ្មៅ ៖1-ដាក់បង្គោលភ្លើងដៃ១ ផ្លូវ110 ចំនួន17បង្គោល (ពីផ្លូវ21B ដល់ ផ្លូវជាតិលេខ2 ) , 2-ដាក់បង្គោលភ្លើងដៃ៤ សរុប17បង្គោល (សួនផ្កាឈូក 3បង្គោល និងសួនមាត់ស្ទឹងត្រើយខាងជើង 14បង្គោល) , 3- ដាក់ដៃអំពូលភ្លើងដៃ១ ផ្លូវ21A ចំនួន 40ដៃអំពូល (ពីគល់ស្ពានព្រែកសំរោង ដល់ព្រំប្រទល់ស្រុកស្អាង), 4-ដាក់បង្គោលភ្លើងដៃ១ ចំនួន7បង្គោល និងដៃអំពូលភ្លើងដៃ១ ចំនួន8ដៃអំពូល នៅជុំវិញផ្សារតាខ្មៅចាស់ ។

ខេត្តកណ្ដាលបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តកណ្ដាលមានអាសយដ្ឋានស្ថិតក្នុងសាលាខេត្តកណ្ដាលចាប់ពីថ្ងៃទី.១៧....ខែ.តុលា..... ឆ្នាំ២០១៧ តទៅនៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាល យ៉ាងយូរបំផុតត្រឹមថ្ងៃទី.១៥..... ខែ.វិច្ឆិកា....ឆ្នាំ២០១៧ វេលាម៉ោង ..០៨.....និង.០០......នាទី។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាល តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៨....និង..០០.....នាទី ថ្ងៃទី ..១៥... ខែ .វិច្ឆិកា.. ឆ្នាំ២០១៧ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាលដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

កណ្ដាល ថ្ងៃទី .១៣.... ខែ តុលា..... ឆ្នាំ២០១៧

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

ម៉ៅ ភិរុណ

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ